សប្តាហ៍ទី
50

រឿងរ៉ាវរបស់លោកពេត្រុស

លោកពេត្រុសបានប្រោសបុរសខ្វិនម្នាក់ឱ្យជាសះស្បើយ។
គាត់អាចក្រោកឈរ និងដើរបានដោយសារព្រះនាមព្រះយេស៊ូ!

ក្រោកឡើង ហើយដើរទៅ!

ថ្ងៃមួយ ពេលលោកពេត្រុស និងលោកយ៉ូហានកំពុងដើរទៅព្រះវិហារ មានបុរសខ្វិនម្នាក់អង្គុយសុំទាននៅមាត់ទ្វារ។

លោកពេត្រុសបាននិយាយថា៖ "ខ្ញុំគ្មានប្រាក់ ឬមាសទេ តែអ្វីដែលខ្ញុំមាន ខ្ញុំនឹងឱ្យអ្នក គឺក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត ជាអ្នកស្រុកណាសារ៉ែត ចូរក្រោកឡើង ហើយដើរទៅ!"។

បុរសនោះក៏ក្រោកឡើង ហើយចាប់ផ្តើមដើរ! មនុស្សម្នាបាននាំគ្នាសរសើរតម្កើងព្រះជាម្ចាស់។
[កិច្ចការ៣:១-១០]





សម្ភារៈ


ក្រដាសព្រីនរូបមនុស្ស


ខ្មៅដៃពណ៌ ហ្វឺតពណ៌ កូលំរទៀន


កន្ត្រៃ ការ


ដែកខ្ជាស់

របៀបធ្វើសកម្មភាព

1. ផាត់ពណ៌លើរូបមនុស្សឱ្យបានស្អាត។
2. កាត់រូបដៃ និងជើង ចេញតាមគែម។
3. យកដែកខ្ជាស់មកខ្ជាស់ភ្ជាប់ដៃ និងជើង ទៅនឹងដងខ្លួន។
4. កាត់រូបគំនូរទាំងនោះចេញតាមគែម។
5. តុក្កតាអាចកម្រើកបានរបស់យើង រួចហើយ!



ការពង្រីកសកម្មភាព

- សាកល្បងតុបតែងសម្លៀកបំពាក់ដោយប្រើពណ៌ផ្សេងៗគ្នាឱ្យបានច្រើន។
- លេងល្បែងដើរតួ (Role-play) ដោយប្រើតុក្កតានេះលេងជាមួយមិត្តភក្តិ។
- សាកល្បងធ្វើតុក្កតាច្រើនតួអង្គ ដើម្បីបង្កើតជារឿងនិទានមួយ។
- សាកល្បងគូរមឹកមុខតុក្កតា ឱ្យមានអារម្មណ៍ប្លែកៗពីគ្នា។

Tip សម្រាប់គ្រូ

- គ្រូត្រូវស្វែងរកទិញ និងរៀបចំ "ដែកខ្ជាស់" ទុកជាមុនឱ្យហើយ។
- ត្រង់ចំណុចសន្លាក់ដៃជើង កុំឱ្យខ្ជាស់តឹងពេក ដើម្បីឱ្យតុក្កតាអាចកម្រើកបានស្រួល។
- សូមកាត់ប្រវែងដៃ និងជើងតុក្កតា កុំឱ្យវែងពេក។
- ក្រោយពេលធ្វើរួច ទុកពេលឱ្យកុមារកាន់តុក្កតាកម្រើកលេងដោយសេរី និងជួយរម្លឹកពួកគេពីរបៀបដែលបុរសខ្វិនអាចក្រោកដើរបាន។